**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៤)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ១៧ ០៥២នាក់ នៃរោងចក្រ សហគ្រាស ទាំង៥០ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖

- ៦១ ៥០០រៀល (១៥ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២៣ ០០០រៀល (៣០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦៤ ០០០រៀល (៤០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ ដើម្បីចៀសវាងការលំបាកក្នុងការបង្វិលថវិកាសងរាជរដ្ឋាភិបាលវិញ ក្នុងករណីរោងចក្រ សហគ្រាសសុំចូលធ្វើការមុនកាលកំណត់នៃរយៈពេលព្យួរកិច្ចសន្យាការងារ នោះប្រាក់ឧបត្ថម្ភនឹងត្រូវចែកចេញជា ២ដង សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងារចាប់ពី ២១ថ្ងៃ ដល់ ១ខែ, និងត្រូវបែងចែកជា ៤ដង សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ដោយក្នុង ១ដង ស្មើនឹងថវិកាចំនួន ៨២ ០០០រៀល (២០ដុល្លារអាមេរិក)។

ក្រសួងសូមរំឮកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៥០ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួនជាបន្ទាន់ដោយផ្អែកលើខ្លឹមសារនៃសេចក្តីណែនាំលេខ០៤៥/២០ របស់ក្រសួង។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ អង្គារ ៤រោច ខែ ជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល

## ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២០

## បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ចំនួន ៥០ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 34 |
| 1 | ក្រុមហ៊ុនជីន ចាយ ហ៊ាន បើក ម៉ាឃីង (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 2 | ក្រុមហ៊ុនវុផុងអ៊ីនដាសស្ទ្រៀល | ភ្នំពេញ |
| 3 | ក្រុមហ៊ុនអេសអ៊ីគីអាយអេ (ខេមបូឌា) ហ្គាមេន ឯ.ក | ភ្នំពេញ |
| 4 | ក្រុមហ៊ុនសានស៊ូ ខ្លូស៊ីង (ខេមបូឌា)ឯ.ក | ភ្នំពេញ |
| 5 | ក្រុមហ៊ុនខ្ទុត វើលដ៍ ថយស៍ ឯ.ក | ភ្នំពេញ |
| 6 | ក្រុមហ៊ុនម៉ាកាឡូត ហ្គាមិន (ខេមបូឌា) សាខាទី ១ | ភ្នំពេញ |
| 7 | ក្រុមហ៊ុនស៊ីម៉ូនី អេស៊ីស៊ី ខឹលេកស៊ិន | ភ្នំពេញ |
| 8 | ក្រុមហ៊ុនថុង ឆាវ អេនធើប្រាយ (ខេមបូឌា) អិលធីឌី | ភ្នំពេញ |
| 9 | ក្រុមហ៊ុនហ្វអេវើ ហ្គូដ ព្រីនធីង | ភ្នំពេញ |
| 10 | ក្រុមហ៊ុនវី.ស៊ី.អូ.អេហ្វ.អេហ្វ អឺភែរើល ឯ.ក | ភ្នំពេញ |
| 11 | ក្រុមហ៊ុនក្រាគស៍ អឺភែរើល (ខេមបូឌា) ខូអិលធីឌី | ភ្នំពេញ |
| 12 | រោងចក្រកាត់ដេរសម្លៀកបំពាក់ យូ.ឌី.អេស ហ្គាមេន | ភ្នំពេញ |
| 13 | ក្រុមហ៊ុន អ៊ិនធើ ហ្វូបវែល ហ្គាមេន ខូអិលធីឌី | ភ្នំពេញ |
| 14 | ក្រុមហ៊ុនឌី&ជេ (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 15 | ក្រុមហ៊ុនហ៊ី លី តូ និតធីង ខូ អិលធីឌី | ភ្នំពេញ |
| 16 | ក្រុមហ៊ុនប្រូដខ្សែនខេមបូឌាហ្គាមែនអ៊ិនឌិសស្ទ្រី | ភ្នំពេញ |
| 17 | ក្រុមហ៊ុនភីភីអិន ភីសយ អឹថយខូអិលធីឌី | កណ្តាល |
| 18 | ក្រុមហ៊ុនគេហ្វ៊ូអាំប្រេឡាខូអិលធីឌី | កណ្តាល |
| 19 | ក្រុមហ៊ុនជា វ៉ុង ព្រីនធីង & អឹមប្រូយឌើរី | កណ្តាល |
| 20 | ក្រុមហ៊ុនលៀនហ្វា (ខេមបូឌា) ហ្គាមេន | កណ្តាល |
| 21 | ក្រុមហ៊ុនឃី ដា មេនូហ្វេកឆឺរើ | កណ្តាល |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 22 | ក្រុមហ៊ុនចុង យ៉ូវ | កណ្តាល |
| 23 | ក្រុមហ៊ុនចិចសាន់(ខេមបូឌា)នីតធីង វ៉ើសុីង ដាយអុីង អេន ព្រីនធីង ឯ.ក | កំពង់ស្ពឺ |
| 24 | ក្រុមហ៊ុនញូនាំមើ ឡាក់ហ្កេដ អេនវ៉ើក (ខេមបូឌា) មេនូហ្វេកធើរីង ឯ.ក | កំពង់ស្ពឺ |
| 25 | ក្រុមហ៊ុនមីង ហ្វៃ អេនធើប្រាយ(ខេមបូឌា)ឯ.ក. | កំពង់ស្ពឺ |
| 26 | ក្រុមហ៊ុនអិមអេ ហ៊ែនវើក (ខឹមបូឌា)ខូអែលធីឌី | កំពង់ស្ពឺ |
| 27 | ក្រុមហ៊ុនហ្គ្រេត ភីស លីមីធីត | កំពង់ស្ពឺ |
| 28 | ក្រុមហ៊ុនខេមបូឌានសុីកនេតឈើរ ថេកស្តាយ ឯ ក | ស្វាយរៀង |
| 29 | ក្រុមហ៊ុនកៅវើ ស្ព៊ត អិលធីឌី | ស្វាយរៀង |
| 30 | ក្រុមហ៊ុនយីងម៉េកឃើ(ខេមបូឌា)ហ្វូតវែរ | ស្វាយរៀង |
| 31 | ក្រុមហ៊ុនអុីលីត (ខេមបូឌា) ខូអិលធីឌី | ស្វាយរៀង |
| 32 | ក្រុមហ៊ុនធី.ខេ ហ្វាមេន សុីសុផុន | បន្ទាយមានជ័យ |
| 33 | ក្រុមហ៊ុនឡាយហ្វេងអៅដរ(ខេមបូឌា)ឯ.ក | តាកែវ |
| 34 | ក្រុមហ៊ុនណាតផាក (ខេមបូឌា) ឯ.ក | ព្រះសីហនុ |
| ខ. វិស័យទេសចរណ៍ | | 16 |
| 35 | ក្រុមហ៊ុនអេមខេត (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 36 | ក្រុមហ៊ុនសហគ្រាស-គ្រឹះស្ថាន ផ្លេនថេសិន ហូថេល | ភ្នំពេញ |
| 37 | សណ្ឋាគាររ៉ាហ្វិលរ៉ូយ៉ាល់ | ភ្នំពេញ |
| 38 | ផ្ទះសំណាក់ប្លូមហ្គានិន | សៀមរាប |
| 39 | ក្រុមហ៊ុនណាវូទូ ទ្រីម | សៀមរាប |
| 40 | ក្រុមហ៊ុនរេសចឹរេន ខូឡិចហ្សិន | សៀមរាប |
| 41 | ក្រុមហ៊ុនទន្លេសាបចៅផាយ៉ា( ភោជនីយដ្ឋានទន្លេសាប) | សៀមរាប |
| 42 | ក្រុមហ៊ុនអាហ្សូណា កាហ្វេធើរ៉ា | សៀមរាប |
| 43 | សណ្ឋាគារសុខាសៀមរាប | សៀមរាប |
| 44 | ក្រុមហ៊ុនអេច ឌី រ៉ក កាហ្វេ & សប | សៀមរាប |
| 45 | ក្រុមហ៊ុនចាយ៉ាហៅស៍រីវើរផាក សៀមរាប ឯ.ក | សៀមរាប |
| 46 | សណ្ឋាគារ សុខាអង្គរ | សៀមរាប |
| 47 | ក្រុមហ៊ុនភូមិបៃតង (ខេមបូឌា) | សៀមរាប |
| 48 | រមណីយដ្ឋានឆ្នេរសុខា | ព្រះសីហនុ |
| 49 | ក្រុមហ៊ុនថ្សូង ឌីវេឡុបមេន | ព្រះសីហនុ |
| 50 | ក្រុមហ៊ុនហេនសួគ៌សុខា | កំពត |